ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Inform-សជណ/ 29-08-22/វៃ-បល-P.97

អគ្គិសនីកម្ពុជា

លេខ: ៤៩៣៩ សជណ.អក.បប

# សេចក្តីជូនដំណឹង
## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើសបុគ្គលិក ចំនួន០៤រូប ដើម្បីចូលបម្រើការងារនៅតាមបណ្តាការិយាល័យ-អង្គភាព នៃនាយកដ្ឋានអាជីវកម្មចែកចាយ ដូចខាងក្រោម :

*- **លក្ខណៈសម្បត្តិបេក្ខជន** :

ក- បុគ្គលិកស្រង់ថាមពលអគ្គិសនីពីនាឡិកាស្ទង់រួមតាមតំបន់ភ្លើង-ប៉ុស្តិ៍(EDC CHECK) ចំនួន០១រូប និង បុគ្គលិកស្រង់ថាមពលអគ្គិសនីពីប្រភពផ្គត់ផ្គង់និងអនុស្ថានីយ ចំនួន០២រូប សម្រាប់ការិយាល័យគ្រប់គ្រងការបាត់បង់ថាមពលអគ្គិសនី :

+បេក្ខជនភេទប្រុស, មានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៣៥ឆ្នាំ

+បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.II.១ ក្នុងពេលសាកល្បងការងារ០៣ខែទទួលបាន៩០%

+កម្រិតជំនាញ : បញ្ចប់ការសិក្សាបរិញ្ញាបត្រវិស្វករអគ្គិសនីឡើងទៅ។

ខ- បុគ្គលិករដ្ឋបាល ចំនួន០១រូប សម្រាប់អង្គភាពបណ្តាញ :

+បេក្ខជនទាំង០២ភេទ, មានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៣៥ឆ្នាំ

+បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ០៣ខែទទួលបាន៩០%

+កម្រិតជំនាញ : បញ្ចប់ការសិក្សាបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចឡើងទៅ។

*- ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជាបេក្ខជនត្រូវទាញយក(Download) ដោយផ្ទាល់ពីក្នុងគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុចព័ត៌មានវិជ្ជាជីវៈ ដោយចុចលើពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជា។

*- បេក្ខជនត្រូវបំពេញពាក្យសុំចូលបម្រើការងារ និងត្រូវអញ្ជើញមកដាក់ពាក្យប្រឡងដោយផ្ទាល់ខ្លួន និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ច្បាប់ដើមមកជាមួយ។ ករណី បេក្ខជនមិនបានអញ្ជើញមកដាក់ពាក្យដោយផ្ទាល់ទេ អគ្គិសនីកម្ពុជា មិនទទួលពាក្យជូនឡើយ។

*- **បេក្ខជនត្រូវមកដាក់ពាក្យ និងភ្ជាប់មកជាមួយនូវ** :

| | |
|---|---|
| - ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារ នៅអគ្គិសនីកម្ពុជា | ចំនួន ០១ ច្បាប់ |
| - ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ | ចំនួន ០១ ច្បាប់ |
| - កិច្ចសន្យាសម្រាប់បំពេញពាក្យសុំចូលបម្រើការងារ និងកិច្ចសន្យាការងារ | ចំនួន ០១ ច្បាប់ |
| - សលាកប័ត្របេក្ខជន | ចំនួន ០១ ច្បាប់ |
| - ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ | ចំនួន ០១ ច្បាប់ |
| - តារាងពិន្ទុ (TRANSCRIPT) | ចំនួន ០១ ច្បាប់ |
| - ច្បាប់ដើម និងច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន | ចំនួន ០១ ច្បាប់ |

អគ្គិសនីកម្ពុជា: #២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ: (៨៥៥) ២៣ ៧២៣ ៩៧១ - ៧២៤ ៧៧១

*- ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធ I នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រឡងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម។

*- **ទីកន្លែងទទួលពាក្យ** : សាលប្រជុំនាយកដ្ឋានរដ្ឋបាល នៅកីឡដ្ឋានបាល់ទាត់អគ្គិសនីកម្ពុជា (អតីតរោងចក្រអគ្គិសនីទី៤)។

ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២ រៀងរាល់ថ្ងៃធ្វើការ <u>ពេលព្រឹក</u> ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០ <u>ពេលល្ងាច</u> ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០។

*- **<u>ព័ត៌មានផ្សេងៗ</u>** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៨៧១ និង ០២៣ ៧២៤ ៧៧១។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ ២០២២

**ជ. រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកអគ្គិសនីកម្ពុជា**
**អគ្គនាយករង**

កេង_គន្ធា

**<u>បញ្ជាក់</u>**

- សេចក្តីជូនដំណឹងនេះ ធ្វើការផ្សព្វផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុច " ព័ត៌មានវិជ្ជាជីវៈ " ។